សារលិខិតគណៈប្រធានទីមួយ



ដោយប្រធាន
ដាល្លិន អេក អូក
ទីប្រឹក្សាទីមួយក្នុង
គណៈប្រធានទីមួយ

# ការចែកចាយដំណឹងល្អ

ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទបានត្រាស់បង្គាប់ពួកសិស្សរបស់ទ្រង់ ឲ្យចែកចាយដំណឹងល្អជាមួយមនុស្សគ្រប់រូបនៅលើផែនដីនេះ ។ ទ្រង់បានមានបន្ទូលថា

« ចូរអ្នករាល់គ្នាទៅពេញសព្វក្នុងលោកីយ៍ទាំងមូល ហើយផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ » ( ម៉ាកុស ១៦:១៥ ) ។



យើងត្រូវការសមាជិកសាសនាចក្រគ្រប់រូប ជួយយកដំណឹងល្អទៅកាន់ពិភពលោកទាំងមូល ។

នេះគឺជារបៀបមួយចំនួនដែលអ្នកអាចជួយបាន ៖

១. **ស្រឡាញ់** មនុស្សគ្រប់គ្នាដូចជាបងប្អូនប្រុសស្រីរបស់អ្នក ដូចព្រះយេស៊ូវគ្រីស្ទបានបង្រៀន ។
២. **គោរពតាមព្រះបញ្ញត្តិ** ដូច្នេះអ្នកអាចក្លាយជាគំរូល្អ ។
៣. **អធិស្ឋាន** ដើម្បីដឹងថា តើនរណាត្រៀមខ្លួនរួចជាស្រេចដើម្បីរៀនដំណឹងល្អ និងអធិស្ឋានឲ្យដឹងពីរបៀបដែលអ្នកអាចចែកចាយដំណឹងល្អជាមួយពួកគេ ។
៤. **ជួយមនុស្សដទៃ** ឲ្យរៀនបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។

កិច្ចការផ្សព្វផ្សាយសាសនាមានន័យថា មានអត្តចរិតនៃសេចក្ដីស្រឡាញ់ និងជួយមនុស្សដទៃ ។ ទោះបីមនុស្សដទៃទៀតឆ្លើយតបបែបណាក្ដី អ្នកគឺជាអ្នកផ្សព្វផ្សាយសាសនាមានជោគជ័យម្នាក់ ប្រសិនបើអ្នកចែកចាយដំណឹងល្អដោយសេចក្ដីស្រឡាញ់ ។ ●

*កែសម្រួលមកពី « ការចែកចាយដំណឹងល្អដែលបានស្ដារឡើងវិញ »* Liahona *ខែ វិច្ឆិកា ឆ្នាំ២០១៦ ទំព័រ ៥៧–៦០ ។*

## ការចែកចាយដោយសេចក្ដីស្រឡាញ់

តើអ្នកអាចបង្ហាញសេចក្ដីស្រឡាញ់របស់អ្នកនាថ្ងៃនេះយ៉ាងដូចម្ដេច ? សូមផ្គូផ្គងរូបភាពនីមួយៗជាមួយនឹងលេខនៅក្នុងសារលិខិតរបស់ប្រធានអូក ។

